**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើង ការិយាល័យកម្មសិទ្ធិឧស្សាហកម្ម នៃនាយកដ្ឋានបច្ចេកទេសឧស្សាហកម្ម ទៅជានាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម នៃអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

**********

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី២២ ខែ មករា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## សំរេច

**មាត្រា១.-**

ត្រូវបានតម្លើងការិយាល័យកម្មសិទ្ធិឧស្សាហកម្ម នៃនាយកដ្ឋានបច្ចេកទេសឧស្សាហកម្ម ទៅជានាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ចំណុះអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា២.-**

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- អនុវត្តនីតិវិធីសម្រាប់ការផ្ដល់ប្រកាសនីយបត្រតក្កកម្ម ការផ្ដល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងការចុះបញ្ជីគំនូរឧស្សាហកម្ម ។
- អនុវត្តនីតិវិធីសម្រាប់ការគ្រប់គ្រងប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ដែលបានផ្ដល់ និងគំនូរឧស្សាហកម្មដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។
- រៀបចំសេចក្ដីព្រាងច្បាប់ នីតិវិធី និងបទបញ្ញាពាក់ព័ន្ធនឹងការចុះបញ្ជី ការគ្រប់គ្រងគំនូរបង្ហាញនៃសៀគ្វីបង្រួម និងប្រភេទថ្មីនៃពូជរុក្ខជាតិ ។
- អនុវត្តនីតិវិធីសម្រាប់ការចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួម និងប្រភេទថ្មីនៃពូជរុក្ខជាតិ ។
- អនុវត្តនីតិវិធីសម្រាប់ការគ្រប់គ្រងគំនូរបង្ហាញនៃសៀគ្វីបង្រួម និងប្រភេទថ្មីនៃពូជរុក្ខជាតិដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។
- ចុះផ្សាយក្នុងព្រឹត្តិបត្រផ្លូវការតាមនីតិវិធី អំពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ គំនូរឧស្សាហកម្ម គំនូរបង្ហាញនៃសៀគ្វីបង្រួម និងប្រភេទថ្មីនៃពូជរុក្ខជាតិ ដែលបានផ្ដល់ និងបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។
- អនុវត្តគោលនយោបាយ និងផែនការក្នុងការពង្រឹងការការពារសិទ្ធិលើកម្មសិទ្ធិឧស្សាហកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។
- ផ្សព្វផ្សាយ និងប្រើប្រាស់ពត៌មានស្ដីពីកម្មសិទ្ធិឧស្សាហកម្ម ធ្វើជាឧបករណ៍សម្រាប់ជំរុញការច្នៃប្រឌិតថ្មី ការបង្កើតតក្កកម្ម ការស្រាវជ្រាវ ក្នុងគោលបំណងអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិជ្ជា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។
- អនុវត្តតាមនីតិវិធីក្នុងការចុះបញ្ជីភ្នាក់ងារ ដែលប្រកបអាជីវកម្មធ្វើជាតំណាងរបស់អ្នកដាក់ពាក្យសុំ ក្នុងការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម ដែលស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រង របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។
- សម្រុះសម្រួលវិវាទពាក់ព័ន្ធនឹងកម្មសិទ្ធិឧស្សាហកម្ម ដែលស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រង របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល តាមសំណើ ។
- សម្របសម្រួល និងធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ និងអង្គការអន្តរជាតិលើការងារកម្មសិទ្ធិឧស្សាហកម្ម ដែលស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា៣.-**

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ត្រូវបានដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**មាត្រា៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធអនុក្រឹត្យលេខ ៤៧ អនក្រ.បក
ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៣

## អង្គការលេខរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

